# តើកំពុងស្វែងរក ការធានារ៉ាប់រងសុខភាពមានដំឡៃថោក ឬដោយឥតគិតថ្លៃឬ?



## វាមានដំណើរការយ៉ាងណា

**OHP Standard ផ្តល់ការធានារ៉ាប់រងសុខភាពដោយឥតគិតថ្លៃ ឬ មានដំឡៃថោក សំរាប់ប្រជាជននៅរដ្ឋ Oregon ដែល :**

- **ពុំមានការធានារ៉ាប់រង ការថែទាំសុខភាព***
- **មានអាយុ 19 ឆ្នាំ ឬចាស់ជាង***
- **ពុំមានផ្ទៃពោះ***
- **មានប្រាក់ចំណូលតិច***

ពីព្រោះតែពុំមានការបើកចុះឈ្មោះគ្រប់គ្រាន់ ឲ្យស្រប តាមសេចក្តីត្រូវការ របស់មនុស្សម្នាក់ៗ បានជា DHS កំពុងតែបង្កើតបញ្ជីមួយ ដើម្បីកត់ប្រជាជនណាដែល ចង់ដាក់ពាក្យសុំ OHP Standard ។ អ្នកត្រូវតែដាក់ឈ្មោះរបស់អ្នកនៅក្នុងបញ្ជីបំរុងទុក ក្នុងកំឡុងពេលពីថ្ងៃទី 28 ខែមករា - ថ្ងៃទី 29 ខែកុម្ភៈ ឆ្នាំ 2008 ។

DHS នឹងជ្រើសឈ្មោះព្រាវៗចេញពីបញ្ជីនោះជាប្រចាំខែ ចាប់ផ្តើមក្នុងខែមីនា ។ បើឈ្មោះរបស់អ្នកត្រូវបានជ្រើស DHS នឹងផ្ញើក្រដាសបំពេញដើម្បីដាក់ពាក្យសុំ OHP Standard ទៅឲ្យអ្នក ។ បើអ្នកដាក់ពាក្យសុំ ហើយមានសិទ្ធិទទួល អ្នកនឹងបានចុះឈ្មោះក្នុង OHP Standard ។

DHS ចង់ឲ្យអ្នកមានឯករាជ្យម្ចាស់ការ មានសុខភាពល្អ និងមានក្តីសុខ ។ គំរោង Oregon Health Plan អាចជួយអ្នកឲ្យធ្វើការនោះកើត ។





## ចូរចាប់ផ្តើម

***មានមធ្យោបាយបីយ៉ាង ដើម្បីឲ្យមានឈ្មោះនៅក្នុងបញ្ជីបំរុងទុក :***

### បំពេញសំណើ តាមអ៊ិនទ័រណិត ។

មើលបញ្ជីបំរុងទុកសំរាប់ OHP Standard នៅលើវ៉ិបសៃ នៅឯ www.oregon.gov/DHS/open ហើយបញ្ចូលព័ត៌មានរបស់អ្នក តាមអេឡិកត្រូនិក ។

### ផ្ញើសំណើ ។

បំពេញក្រដាសបំពេញសំណើ បំរុងទុកសំរាប់ OHP Standard ។ ក្រដាសបំពេញគឺមាននៅឯ DHS ឬមាននៅ តាមការិយាល័យភ្នាក់ងារខាងវិស័យជរាវ័យ (AAA) នៅតាមក្រសួងសុខាភិបាលខោនធី និងនៅតាមមន្ទីរពេទ្យធំៗ និងមន្ទីរព្យាបាល ។

### ចុះឈ្មោះតាមទូរស័ព្ទ ។

ទូរស័ព្ទទៅលេខ 800-699-9075 ឬ 503-378-7800 (TTY) ពីថ្ងៃច័ន្ទរហូតដល់ថ្ងៃសុក្រ ពីម៉ោង 7:00 ព្រឹក ដល់ 7:00 យប់ ។ បើអ្នកមិនអាចទូរស័ព្ទទៅក្នុងកំឡុងពេលម៉ោងដែលបានកត់នេះទេ អ្នកអាចឲ្យនរណាម្នាក់ទូរស័ព្ទជំនួសអ្នកបាន – គេត្រូវការតែឈ្មោះ ថ្ងៃខែឆ្នាំកំណើត ហើយនិងអាសយដ្ឋានផ្ញើសំបុត្រ របស់អ្នកតែប៉ុណ្ណោះ ។

### វាងាយស្រួល វាសមរម្យ ចូរឲ្យមានឈ្មោះនៅក្នុងបញ្ជី !

**បញ្ជីបំរុងទុក គឺបើកចុះឈ្មោះតែពីថ្ងៃទី 28 ខែមករា - ថ្ងៃទី 29 ខែកុម្ភៈ ឆ្នាំ 2008 ប៉ុណ្ណោះទេ ។**

DHS
Oregon Department of Human Services

Oregon HEALTH PLAN

OHP 3206 (Rev. 01/2008) – Cambodian

* ព័ត៌មាននៅខាងលើពាក់ព័ន្ធទៅលើតែ OHP Standard ប៉ុណ្ណោះទេ ។ កញ្ចប់អត្ថប្រយោជន៍ផ្សេងៗទៀត ដូចជាការរ៉ាប់រងស្ត្រីមានផ្ទៃពោះ ឬមនុស្សអាយុក្រោម 19 ឆ្នាំ មានសេចក្តីដំរូវនៃសិទ្ធិទទួលខុសពីគ្នា ហើយតែងតែបើកចុះឈ្មោះជានិច្ច ។ ដើម្បីឲ្យបានជ្រាប ក្រែងលោអ្នកមានសិទ្ធិទទួលកញ្ចប់អត្ថប្រយោជន៍ណាមួយទាំងនេះ ត្រូវបំពេញក្រដាសដាក់ពាក្យសុំ OHP ។ ក្រដាសដាក់ពាក្យសុំ OHP គឺមានផ្តល់ជូន ដោយទូរស័ព្ទទៅលេខ 800-359-9517 ឬអាចយកបាននៅតាមសាខាការិយាល័យ DHS ។